| | | |
|---|---|---|
| **Name of Media** | **:** | Khmer Conscience Newspaper, Cambodia |
| **Date of Article** | **:** | 1 July 2005 |
| **Author** | **:** | Oav Cago |
| **Pages** | **:** | 2 pages (original and English translation) |
| **Notes** | **:** | Article on Comparing Access to Justice workshop |

# អ្នកជំនាញការច្បាប់អាស៊ី និងអឺរ៉ុបពិភាក្សា អំពីដំណើរឆ្ពោះទៅរកភាពយុត្តិធម៌

អ្នកជំនាញការច្បាប់ មកពីក្រុមប្រឹក្សាច្បាប់ ស្ថាប័នច្បាប់ សិទ្ធិមនុស្ស អ្នកស្រាវជ្រាវ និងអ្នកសិក្សានៃបណ្តាប្រទេសនៅអាស៊ី និងអឺរ៉ុបចំនួន ២៥នាក់ បានមកជួបជុំចូលរួមពិភាក្សាគ្នានៅក្នុងសិក្ខាសាលា ស្តីអំពីដំណើរឆ្ពោះទៅរកយុត្តិធម៌ នៅប្រទេសកំពុងធ្វើអន្តរកាលនៅអាស៊ី និងអឺរ៉ុប ។

សិក្ខាសាលា រយៈពេល២ថ្ងៃ នៅទីក្រុងបូហ្គោ ប្រទេសឥណ្ឌូនេស៊ី ពីថ្ងៃទី២៧-២៨ ខែមិថុនា ឆ្នាំ២០០៥ សហការរៀបចំឡើង ដោយមូលនិធិអាស៊ី-អឺរ៉ុប (Asia-Europe Foundation), មជ្ឈមណ្ឌលហាប៊ីប៊ី (Habibie Center) និងមូលនិធិហាន់ស៍ស៊ីដែល (Hanns Seidel Foundation) ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសហការពិភាក្សា ដើម្បីពង្រឹងប្រសិទ្ធភាព ដំណើរឆ្ពោះទៅរកយុត្តិធម៌ នៅក្នុងប្រទេសនៃតំបន់ទាំងពីរ ។

សិក្ខាសាលានោះ ផ្តោតទៅលើប្រធានបទបីសំខាន់ៗគឺ

-មធ្យោបាយ ដើម្បីធានាលើដំណើរឆ្ពោះ ទៅរកភាពយុត្តិធម៌តាមរដ្ឋធម្មនុញ្ញ និងកំណែទម្រង់ច្បាប់ តាមបទពិសោធន៍កន្លងមក ។

-សិក្សាលើករណី នៃប្រទេសនៅអាស៊ី និងអឺរ៉ុប អំពីរបៀបដែលស្ថាប័នច្បាប់ និងស្ថាប័នសិទ្ធិមនុស្ស រួមចំណែកធ្វើការឆ្ពោះ ទៅរកភាពយុត្តិធម៌ ។

-ការពង្រឹងយុត្តិធម៌ បើកចំហ និងការផ្តល់សិទ្ធិអំណាចដល់សាធារណៈ ។

លើសពីនេះ គោលបំណងចំបងនៃសិក្ខាសាលារយៈពេល២ថ្ងៃនេះ គឺដើម្បីកំណត់នូវបញ្ហាដំណោះស្រាយ និងដំណើរការជាបន្តបន្ទាប់ សំរាប់គំរោងសហប្រតិបត្តិការ អន្តរជាតិដែលទាក់ទងនឹងស្ថាប័ន របស់អ្នកចូលរួម ដើម្បីពង្រឹងដំណើរការឆ្ពោះទៅរកយុត្តិធម៌ ។

មូលនិធិអាស៊ី និងអឺរ៉ុប បានបង្កើតឡើងនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដើម្បីបង្កើនទំនាក់ទំនង និងភាពយោគយល់គ្នា រវាងបណ្តាប្រជាជននៅអាស៊ី និងអឺរ៉ុប តាមរយៈការផ្លាស់ប្តូរចំណេះដឹង វប្បធម៌ និងរវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។

| | | |
|---|---|---|
| **Name of Media** | **:** | Khmer Conscience Newspaper, Cambodia |
| **Date of Article** | **:** | 1 July 2005 |
| **Author** | **:** | Oav Cago |
| **Pages** | **:** | 2 pages (original and English translation) |
| **Notes** | **:** | Article on Comparing Access to Justice workshop |

Translation

## Asian and European Law Experts talk over Access to Justice.

More than 25 scholars, researchers, NGO representatives and policy-makers in the field of Justice from Asia and Europe have discussed in the workshop on Comparing Access to justice in Asian and European Transitional Countries.

The two-day workshop in Bogor, Indonesia from 27 to 28 June 2005 which was co-organized by the Asia Europe Foundation, the Habibie center and Hanns-Seidel foundation aim to provide chance to participants to compare their experience in legal reform and facilitate public access to justice in the two regions.

The workshop focus on three main topic:

- Guaranteeing Access to Justice through Constitutional and Legal Reforms: How could the vestiges of the past be addressed?
- Case Studies Across Asia and Europe: How well have the ombudsman, human rights commissions, and free legal aid mechanisms worked?
- Creating a Culture of Openness and Public Empowerment: Are Words Enough?

The main objective of the workshop is to identify specific issues and concrete follow-ups for international cooperation projects involving the institutions represented by the participants. Although the workshop's timing was short, participants have discussed and shared their idea broadly come out with fruitful outcome.

Asia-Europe Foundation was established in 1997 seeks to promote better mutual understanding between Asia and Europe through greater intellectual, cultural and people-to-people exchanges. (end)